**តើមានអ្វីកើតឡើងបើអតិថិជនព្យាយាមចូលតំបន់លេងល្បែងស៊ីសងនៅពេលដែលគាត់ជាប់ បម្រាម?**
ក្រសួងកិច្ចការផ្ទៃក្នុងអាចផ្តន្ទាទោស និងផាកពិន័យអតិថិជននេះ។ ក្នុងករណីស្ថិតនៅក្នុងតំបន់លេងល្បែងស៊ីសងរបស់ SkyCity អតិថិជនអាចទទួលបានលិខិត “Requirement to Leave the Premises” Notice (RTLP) (តម្រូវឲ្យចាកចេញពីបរិវេណ) ឬលិខិត Trespass Notice (លិខិតព្រមានចូលតំបន់ហាមឃាត់ )។ នេះមានន័យថាគាត់មិនអាចចូលទៅក្នុងកន្លែងណាមួយនៃអគាររបស់ SkyCity (រួមទាំងតំបន់លេងល្បែងស៊ីសង) ក្នុងរយៈពេលពីរឆ្នាំទៀត។ បើអតិថិជនបំពានលើលិខិត Trespass Notice (លិខិតព្រមានចូលតំបន់ហាមឃាត់) គាត់នឹងអាចនឹងត្រូវសមត្ថកិច្ចប្រទេសនូវែលសេឡង់ចាប់ខ្លួន។

**តើអតិថិជននៅតែអាចទទួលខិតប័ណ្ណបញ្ចុះតម្លៃពិសេសតាមសារអេឡិចត្រូនិចដែរឬទេ?**
អត់ទេ។ ទោះជាយ៉ាងណាក៏ដោយ SkyCity ត្រូវចំណាយរយៈពេលខ្លី ដើម្បីធ្វើបច្ចុប្បន្នភាពលើកំណត់ត្រារបស់ខ្លួន ហើយលុបចោលរាល់ការទំនាក់ទំនងទាំងអស់អំពីការ**បញ្ចុះតម្លៃពិសេស** និងសកម្មភាពនានារបស់ខ្លួនជូនអតិថិជន។ សូមទាក់ទងមកយើងខ្ញុំ ប្រសិនបើលោកអ្នកមានក្តីកង្វល់ណាមួយអំពី**ខិតប័ណ្ណបញ្ចុះតម្លៃពិសេស**របស់ SkyCity ។

**តើអតិថិជននៅតែអាចមកភោជនីយដ្ឋាន និងបារបានដែរឬទេ?**
បម្រាមនេះត្រូវហាមឃាត់អតិថិជនមិនឲ្យចូលមកតំបន់លេងល្បែងស៊ីសងរបស់ SkyCity Auckland និង SkyCity Hamilton ព្រមទាំង បារ និងភោជនីយដ្ឋានណាមួយនៅក្នុងតំបន់ទាំងនោះ។ អតិថិជននៅតែអាចទៅលេងបារ ភោជនីយដ្ឋាន សណ្ឋាគារ និងមជ្ឈមណ្ឌល សន្និបាតនៅខាងក្រៅតំបន់លេងល្បែងស៊ីសងនៅ SkyCity Auckland និង SkyCity Hamilton បានដដែល។ ប៉ុន្តែនៅឯកាស៊ីណូ SkyCity Queenstown អតិថិជននឹងត្រូវបានហាមឃាត់មិនឲ្យចូលទៅក្នុងទីបរិវេណអគារទាំងមូលនេះទេ។

**តើមានការគាំទ្រអ្វីខ្លះចំពោះអ្នកដែលបានហាមឃាត់?**
SkyCity លើកទឹកចិត្តដល់អតិថិជនដែលជាប់បម្រាមឲ្យជ្រើសរើសអ្នកណែនាំម្នាក់ដើម្បីផ្តល់ការគាំទ្រ និងអ្នកផ្តល់ប្រឹក្សាជំនាញម្នាក់ ដើម្បីណែនាំ និងជួយពួកគេ។ យើងអាចផ្តល់បញ្ជីសេវាប្រឹក្សាដោយឥតគិតថ្លៃ និងរក្សាការសម្ងាត់ ហើយសេវានេះអាចទាក់ទងបាន ២៤ ម៉ោងក្នុងមួយថ្ងៃ។ សេវាប្រឹក្សាក៏មានផ្តល់ជូននូវការប្រែភាសាមួយចំនួនផងដែរ។

**SkyCity AUCKLAND** 0800 SKYCITY (0800 759 2489)

**SkyCity HAMILTON** 07 834 4900

**SkyCity QUEENSTOWN** 03 441 0400

ផ្នែកទទួលខុសត្រូវបដិសណ្ឋារកិច្ចរបស់ **SkyCity**

អ៊ីម៉ែល៖ hostresponsibility@skycity.co.nz

ផ្ញើ សារទៅលេខ **8006** ឬ
សូមទាក់ទងតាមខ្សែទូរស័ ព្ទ
ជំនួយបញ្ហាល្បែងស៊ី សង
**0800 654 655**
(ឥតគិ តថ្លៃ និ ងរក្សាការសម្ងាត់ ២៤ ម៉ោង)

13239 02/2020



# តើមានក្តីកង្វល់ពីការលេងល្បែងស៊ីសងរបស់បុគ្គលណាម្នាក់ឬ? **SkyCity អាចជួយបាន។**

---

## ការប្តេជ្ញាចិត្តរបស់យើងចំពោះអតិថិជនរបស់យើង

---

R20 GAME RESPONSIBLY

SkyCity ទទួលខុសត្រូវយ៉ាងម៉ឺងម៉ាត់ក្នុងនាមជាម្ចាស់ផ្ទះ៖ សុវត្ថិភាព និងសុខុមាលភាពរបស់អតិថិជន គឺជាអាទិភាពចម្បង។ យើងក៏មានកាតព្វកិច្ចផ្លូវច្បាប់ដ៏សំខាន់ក្នុងនាមជាអ្នកបើកកាស៊ីណូដែលស្ថិតនៅក្រោមច្បាប់ Gambling Act 2003 ផងដែរ។

សម្រាប់អតិថិជនខ្លះ ការលេងល្បែងស៊ីសងអាចបណ្តាលឲ្យមានផលអន្តរាយរួមទាំងបញ្ហាហិរញ្ញវត្ថុបញ្ហា ផ្លូវចិត្ត និងបញ្ហាទំនាក់ទំនង។ បើអ្នកមានក្តីកង្វល់អំពីការលេងល្បែងស៊ីសងរបស់សមាជិកគ្រួសារ ឬមិត្តភ័ក្តិណាម្នាក់ SkyCity ចង់ដឹងព័ត៌មានពីលោកអ្នក។

## ខ្ញុំបារម្ភអំពីការលេងល្បែងស៊ីសងរបស់មិត្តភ័ក្តិ។ មិត្តរបស់ខ្ញុំមិនទទួលស្គាល់ថា ខ្លួនគេមានបញ្ហាទេ។ តើ SkyCity អាចជួយអ្វីខ្លះ?

ក្រោមច្បាប់ Gambling Act 2003 SkyCity អាចហាមឃាត់បុគ្គលណាម្នាក់មិនឲ្យចូលតំបន់លេងល្បែងស៊ីសងនៃកាស៊ីណូរបស់ខ្លួនក្នុងប្រទេសនូវែលសេឡង់រយៈពេលរហូតដល់ពីរឆ្នាំ។ នេះ គឺជាវិធានការដ៏សំខាន់មួយដែល SkyCity ត្រូវធ្វើឡើងដើម្បីទប់ស្កាត់ការល្មើស។ អ្នកគួរតែទាក់ទងផ្នែកទទួលខុសត្រូវខាងបដិសណ្ឋារកិច្ចរបស់ SkyCity ដើម្បីពិភាក្សាអំពីនីតិវិធីនេះ។

## តើការដាក់បម្រាមនេះ គឺមានតែមួយជម្រើសគត់មែនទេ?

អត់ទេ - វាគឺជាវិធានការមួយក្នុងចំណោមវិធានការទាំងឡាយ ដែលអាចធ្វើឡើងរួមទាំងការអនុវត្តតាមគោលការណ៍ណែនាំស្តីពីការលេងល្បែងស៊ីសង ដោយមានទំនួលខុសត្រូវ និងចូលរួមក្នុងការប្រឹក្សាពីអ្នកជំនាញ។ សម្រាប់ព័ត៌មានបន្ថែមអំពីវិធានការនានា សូមទាក់ទងតាមខ្សែទូរស័ព្ទជំនួយបញ្ហាល្បែងស៊ីសង (GamblingHelpline) ៖ 0800 654 655 ឬចូលមើលគេហទំព័រ www.gamblinghelpline.co.nz

## តើអ្វីទៅជានីតិវិធីនៃការដាក់បម្រាម?

យើងត្រូវជួបពិភាក្សាជាមួយលោកអ្នក អំពីក្តីកង្វល់របស់លោកអ្នក។ អ្នកគួរតែយកឯកសារភស្តុតាងមកជាមួយដែលអ្នកអាចផ្តល់ (ឧទាហរណ៍ របាយការណ៍គណនីធនាគារ និងវិក្កយបត្រដែលមិនទាន់បង់ប្រាក់) និងរូបថតរបស់បុគ្គលដែលអ្នកព្រួយបារម្ភ។

បន្ទាប់មក SkyCity នឹងធ្វើការសើ ុបអង្កេត។ ជាផ្នែកមួយនៃការសើ ុបអង្កេតនោះ SkyCity អាចសម្រេចចិត្តជួបអតិថិជនដែលពាក់ព័ន្ធដើម្បីពិភាក្សាអំពីការលេងល្បែងស៊ីសងរបស់គាត់។ នៅកិច្ចប្រជុំនេះ SkyCity នឹងមិនលើកឡើងពីទំនាក់ទំនងរបស់អ្នកជាមួយយើងទេ លុះត្រាតែអ្នកបានអនុញ្ញាតឲ្យយើងធ្វើដូច្នេះ។

បើ SkyCity ជឿថា ក្តីកង្វល់របស់អ្នកពិតជាត្រឹមត្រូវ និងពិតប្រាកដ SkyCity នឹងផ្តល់ឱកាសឲ្យអតិថិជននេះដកខ្លួនចេញដោយស្ម័គ្រចិត្តពី SkyCity មួយរយៈ និងរហូតដល់បានបំពេញលក្ខខណ្ឌក្នុងចូលលេងឡើងវិញ។

បើពួកគេមិនយល់ព្រមដកខ្លួនដោយស្ម័គ្រចិត្ត នោះពួកគេ នឹងត្រូវបានជូនដំណឹងថា SkyCity នឹងហាមឃាត់ពួកគេមិនឲ្យចូលលេងក្នុងរយៈពេលអប្បបរមាពីរឆ្នាំ។ ព័ត៌មានលម្អិតរបស់ពួកគេនឹងត្រូវបានកត់ត្រា ហើយថតរូបទុក។ គោលបំណងនៃការថតរូបនេះ គឺដើម្បីជួយ SkyCity កំណត់អត្តសញ្ញាណអតិថិជននេះក្នុងករណីគេព្យាយាមចូលតំបន់លេងល្បែងស៊ីសងម្តងទៀតនៅពេលពួកគេកំពុងតែជាប់បម្រាម។

អតិថិជននេះនឹងត្រូវបានលើកទឹកចិត្តឲ្យជ្រើសយកអ្នកណែនាំម្នាក់ (សមាជិកគ្រួសារ/ក្រុមគ្រួសារ ឬមិត្តភ័ក្តិ) ដែលអាចជួយគេ និង ជ្រើសរើសសេវាប្រឹក្សាដើម្បីចូលរួម។ បើអតិថិជននេះមានប័ណ្ណ Premier Rewards គេនឹងអាចយកពិន្ទុដែលនៅសល់ទៅប្តូរបាន ប៉ុន្តែនៅពេលនោះប័ណ្ណរបស់គេនឹងលែងដំណើរការ។

## តើវាជាការសម្ងាត់ដែរឬទេ?

នីតិវិធីនៃការដាក់បម្រាម គឺជាសេវាកម្មដាច់ដោយឡែកមួយដែលត្រូវបានធ្វើឡើងមិនឲ្យចូលកាស៊ីណូ។ ព័ត៌មានដែលទទួលបានក្នុងអំឡុងពេលអនុវត្តនីតិវិធីនេះគឺជាការសម្ងាត់ ហើយ SkyCity អាចចែករំលែកព័ត៌មាននេះបានតែក្នុងករណីតម្រូវឲ្យធ្វើដូច្នេះ (ដោយច្បាប់ ឬផ្សេងពីនេះ) ឬក្នុងករណីដែល SkyCity ជឿថា ជីវិត ឬសុខភាពរបស់បុគ្គលណាម្នាក់កំពុងប្រឈមនឹងគ្រោះថ្នាក់។

សូមមេចំណាំថា ដោយសារតែបទបញ្ញត្តនៃច្បាប់ Privacy Act 1993 SkyCity នឹងមិនអាចជម្រាបជូនលោកអ្នកអំពីលទ្ធផលរកឃើញ ឬលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួនទេ។

ការចូលរួមរបស់អ្នកនៅក្នុងនីតិវិធីនេះអាចត្រូវបានរក្សាទុកជាការសម្ងាត់ទាំងស្រុង។ បើអ្នកចង់រក្សាការសម្ងាត់ គេនឹងមិនប្រាប់អតិថិជននេះថា អ្នកបានមកជួបយើងដើម្បីដោះស្រាយក្តីកង្វល់របស់អ្នកនោះទេ។

## តើមានលក្ខខណ្ឌអ្វីខ្លះក្នុងការអនុញ្ញាតឲ្យចូលលេងវិញ?

- មិនមានលិខិត Requirement to Leave Premises” (RTLP) (តម្រូវឲ្យចាកចេញពីអគារ) និង / ឬលិខិត Trespass Notice (លិខិតព្រមានចូលតំបន់ហាមឃាត់) មានសុពលភាពដែលចេញជូនអ្នកដោយ SkyCity នៅក្នុងប្រទេសនូវែលសេឡង់។

ប្រសិនបើអតិថិជននេះបំពេញគ្រប់លក្ខខណ្ឌចូលលេងឡើងវិញទាំងនេះ ហើយមានបំណងចង់ត្រឡប់មកលេងកាស៊ីណូណាមួយរបស់ SkyCity វិញគាត់នឹងត្រូវបំពេញទម្រង់បែបបទសុំការអនុញ្ញាតចូលលេងវិញរបស់ SkyCity ។ អតិថិជននេះមិនអាចចូលតំបន់លេងល្បែងស៊ីសងណាមួយរបស់យើងបានទេ រហូតទាល់តែ SkyCity បានអនុម័តពាក្យស្នើសុំរបស់គាត់។

SkyCity ក៏អាចជ្រើសរើសធ្វើការណែនាំពីលក្ខខណ្ឌបន្ថែមទៀតក្នុងការស្នើសុំការអនុញ្ញាតចូលលេងវិញតាមឆន្ទានុសិទ្ធិរបស់ខ្លួន។